# ព្រះវិហារវត្តពុទ្ធានិងគំនូរដើមសម័យសង្គមរាស្ត្រនិយម

វត្តពុទ្ធា ស្ថិតនៅក្នុងភូមិសាស្ត្រនៃឃុំចក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ អ្នកស្រាវជ្រាវយល់ថាព្រះវិហារវត្តពុទ្ធាកសាងឡើងតាំងពីដើមសតវត្សរ៍ទី២០ ជាប្រភេទព្រះវិហារឈើតែគ្មានជញ្ជាំង។ លុះចូលដល់រវាងដើមសម័យសង្គមរាស្ត្រនិយម ព្រះវិហារនេះបានរៀបជញ្ជាំងឥដ្ឋ និងគូរគំនូររឿងរ៉ាវពាក់ព័ន្ធនឹងពុទ្ធប្រវត្តិ ដោយគេឃើញមានបញ្ចូលទិដ្ឋភាពសង្គមក្នុងខ្លឹមសារគំនូរផង។ ក្នុងទសវត្សរ៍ទី៩០ អ្នកស្រុកបានមូលមាត់គ្នាជួសជុលជាថ្មីម្តងទៀត ជាពិសេសការរៀបចំគូរលម្អលើសសរទាំងអស់ ហើយក្រោយមកគេបានជួសជុលគំនូរលើជញ្ជាំងត្រង់ផ្ទាំងខ្លះដែលរលុបខូចខាតខ្លាំង។ មកដល់សព្វថ្ងៃ ព្រះវិហារវត្តពុទ្ធាអាចរាប់បានថាជាសំណង់បេតិកភណ្ឌដ៏មានតម្លៃ ដែលមានគ្រឿងបង្គុំនិងសសរឈើធំៗ នៅស្ថិតស្ថេរគង់វង្ស ស្ទើរតែរកសំណង់ណាប្រៀបប្រដូចបាននៅក្នុងតំបន់ជុំវិញ សម្រាប់ពុទ្ធសាសនិកគោរពបូជាជាច្រើនតំណមក (រូបលេខ១)។



រូបលេខ១ ព្រះវិហារវត្តពុទ្ធាមើលពីជ្រុងអាគ្នេយ៍

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាការពិតគេមើលឃើញថាព្រះវិហារវត្តពុទ្ធា គឺជាសំណង់បុរាណដ៏រឹងមាំ វិសេសក្រៃលែង សង់ឡើងនៅលើខឿនខ្ពស់ ដែលមានដំបូលជាទម្រង់ព្រះវិហារជហ្វាបួន និងបើកល្វែងខាងក្នុងជាប្រឡោះយ៉ាងធំទូលាយ។ ថ្វីបើពុំមានចំណារ ឬកំណត់ត្រាណាចារបញ្ជាក់អំពីកាលបរិច្ឆេទកសាងព្រះវិហារវត្តពុទ្ធា តែអ្នកស្រាវជ្រាវ Daniel Guéret និង Dominique-Pierre Guéret យល់ថាព្រះវិហារនេះកសាងនៅរវាងឆ្នាំ១៩៣៣ រៀបជញ្ជាំងឥដ្ឋនិងគូរគំនូរក្នុងឆ្នាំ១៩៥៩ ហើយបានជួសជុលកែលម្អគំនូរលើសសរឈើទាំងអស់នៅឆ្នាំ១៩៩០។[1]

បច្ចុប្បន្នគេមើលឃើញថា ព្រះវិហារវត្តពុទ្ធាគឺជាព្រះវិហារជហ្វាបួន ប្រក់ក្បឿងស្រកាលេញ និងលម្អដោយនាគចែងតាមចុងចែងនីមួយៗ។ ហោជាងទាំងពីររចនាក្បាច់លម្អអំពីកំបោរបាយអ ដែលគេយល់ថាប្រហែលធ្វើនៅចុងទសវត្សរ៍ទី៥០ ជំនួសហោជាងចាស់។ ប៉ុន្តែហោជាងទាំងពីរមានលក្ខណៈពុំដូចគ្នាឡើយ។ ហោជាងខាងកើតមានផ្ទៃពណ៌ផ្កាឈូក រចនាជារូបព្រះពិស្ណុការគង់លើក្បាលរាហូនៅចំកណ្តាលហោជាង និងព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេស។ ជ្រុងខាងលើមានឆ្លាក់រូបឆ័ត្ររួតបីថ្នាក់(?) និងរំភាយក្រណាត់លម្អផ្នែកខាងក្រោម (រូបលេខ២២)។ រីឯនៅលើហោជាងខាងលិចមានផ្ទៃពណ៌ទឹកប៊ិកចាស់ រូបនៅចំផ្ទៃកណ្តាលទំនងគេឆ្លាក់តាមគំរូព្រះសង្ហារ ដែលតំណាងឱ្យអង្គព្រះមហាក្សត្រជាស្តេចផែនដី ដ្បិតនៅគេឃើញមានមកុដរាជ្យ និងព្រះខ័នរាជ្យតម្កល់លើជើងពាន អមដោយរាជសីហ៍និងគជសីហ៍ឈរកាន់ឆ័ត្ររួត ព័ទ្ធជុំវិញដោយក្បាច់ភ្ញីភ្លើង (រូបលេខ២៣)។



*រូបលេខ២២ ហោជាងខាងកើតនៃព្រះវិហារវត្តពុទ្ធា*



*រូបលេខ២៣ ហោជាងខាងលិចនៃព្រះវិហារវត្តពុទ្ធា*

---

[1] *Daniel Guéret & Dominique-Pierre Guéret 2017: 89*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំពោះរចនាសម្ព័ន្ធផ្នែកខាងក្រោមដំបូល នៅលើជញ្ជាំងខាងមុខនិងខាងក្រោយមានជណ្ដើរឡើងម្ខាងពីរ និងទ្វារម្ខាងពីរដូចគ្នា។ ប៉ុន្តែនៅលើជញ្ជាំងចំហៀងពុំមានទ្វារឡើយ ពោលគឺមានតែបង្អួចម្ខាងប្រាំពីរ ហើយនៅតាមស៊ុមទ្វារនិងបង្អួចនីមួយៗ គេលម្អដោយក្បាច់ពុម្ពស៊ីម៉ងត៍ភ្ជាប់ដោយទេពប្រណម្យនៅកណ្ដាលដូចៗគ្នា។ មិនតែប៉ុណ្ណោះ ដោយសារព្រះវិហារវត្តពុទ្ធាជាព្រះវិហារមានជញ្ជាំងជាប់នឹងសសរបាំងសាច ដូច្នេះនៅផ្នែកខាងក្រៅគេលម្អដោយរូបគ្រុឌតាមក្បាលសសរចែងជញ្ជាំង និងរូបកិន្នរនៅតាមក្បាលសសរចំហៀងទាំងអស់។

ដោយឡែក នៅផ្នែកខាងក្នុងព្រះវិហារគេឃើញមានសសរឈើធំៗចំនួន៦០ដើម ដែលគេរចនាលម្អដោយរូបនាគព័ទ្ធព័ន្ធចុះពីពិតាន និងក្បាច់រចនាផ្សេងៗលាយចម្រុះរូបកិន្នរ រូបសត្វស្វាប និងរូបមនុស្សជាដើម។ អ្វីដែលគួរឱ្យកត់សម្គាល់ នៅតាមគល់សសរខ្លះមានគំនូររូបព្រះយមរាជ រូបហនុមាន ឬរូបសិង្ហជាដើម។ ចំពោះសសរពីរជួរតំបណ្ដោយព្រះវិហារ ដែលស្ថិតនៅអមល្វែងគ្រឹះមានទំហំធំជាងគេ ពោលគឺមានទំហំធំជាងមួយឱបរបស់ក្មេង (មុខកាត់ប្រហែល៥-៦តឹក) (រូបលេខ២៨)។ ចំណែកឯសសររបៀង ហាក់ដូចជាមានទំហំតូចជាសសរអមល្វែងគ្រឹះបន្តិច (រូបលេខ២៩) ហើយសសរតាមជួរជញ្ជាំងគឺមានទំហំតូចជាសសររបៀងបន្តិចដែរ។ ប៉ុន្តែយ៉ាងណាក្ដី សសរឈើក្នុងព្រះវិហារនេះមានទំហំធំៗស្មើររកសសរព្រះវិហារណាប្រៀបពុំបានឡើយ ហើយក្នុងរវាងឆ្នាំ១៩៩០ គេបានគូរលម្អក្បូរក្បាច់ផ្សេងៗដូររៀបរាប់ខាងលើ ព្រមទាំងលាបពណ៌តាមដើងសសរឱ្យមានសណ្ឋានស្មើរតែដូចនឹងសសរបេតុងដែរ។



រូបលេខ២៨ សសរឈើអមល្វែងគ្រឹះ



រូបលេខ២៩ សសររបៀងខាងក្រៅល្វែងគ្រឹះ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ព្រះដីវ៍ខាងក្នុងព្រះវិហារ គេសាងឡើងនៅចន្លោះល្វែងគ្រឹះ តម្កល់លើបល្ល័ង្កខ្ពស់មួយនៅផ្នែកចុងខាងលិច។ ព្រះបដិមាព្រះដីវ៍អង្គនេះ សាងឡើងពីស៊ីម៉ងត៍ក្នុងទម្រង់ជាព្រះពុទ្ធផ្ចាញ់មារ ពោលគឺទ្រង់ព្រះភ្នែន ចុងព្រះហស្តស្តាំគងលើព្រះបាទស្តាំ សំយុងចុះក្រោម ព្រះហស្តឆ្វេងលាផ្ងារដាក់លើព្រះបាទ (រូបលេខ៦)។ ប៉ុន្តែយ៉ាងណាក្តី គេពុំឃើញមានចំណារ ឬព័ត៌មានអ្វីបញ្ជាក់ឱ្យដឹងថាព្រះបដិមាព្រះដីវ៍តម្កល់ក្នុងព្រះវិហារនេះសាងឡើងក្នុងឆ្នាំណាជាក់លាក់ឡើយ។ ចំណែកឯនៅផ្នែកខាងក្រោយបល្ល័ង្ក គេថែមទាំងគូររូបនាងគង្ហីងបួតសក់ដែលយើងតែងឃើញជានិច្ចក្នុងគំនូរត្រង់ព្រះអង្គផ្ចាញ់មារ។ សូមរំលឹកថា អ្នកស្រាវជ្រាវសម្គាល់ឃើញចម្លាក់បង្ហាញត្រង់ឈុតផ្ចាញ់មារ ដែលមានរូបនាងគង្ហីងបួតសក់ភ្ជាប់ជាមួយ គឺយ៉ាងហោចណាស់តាំងពីរវាងសតវត្សរ៍ទី១២ និងបន្តជាហូរហែមកដូចជា ឆ្លាក់នៅប្រាសាទតាព្រហ្មនៅតំបន់អង្គរ ប្រាសាទតាព្រហ្មនៅទន្លេបាទីខេត្តតាកែវ និងប្រាសាទវត្តនគរបាជ័យក្នុងខេត្តកំពង់ចាមជាដើម។[2]



រូបលេខ៦ ព្រះបដិមាព្រះដីវ៍តម្កល់ក្នុងព្រះវិហារវត្តពុទ្ធា

[2] ព្រាប ចាន់ម៉ារ៉ា ២០១៥: ២៤-៣០

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

គំនូរក្នុងព្រះវិហារ ជាទូទៅគេសង្កេតឃើញវិចិត្រករគូរបញ្ចូលព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រខ្មែរ រូបបុគ្គលល្បី និងទិដ្ឋភាពផ្សេងៗក្នុងសង្គម។ គំនូរនៅលើជញ្ជាំងមានពីរជួរ ពោលគឺជួរខាងក្រោមជាឈុតសំខាន់ៗក្នុងជាតក និងជួរខាងលើជាខ្សែរឿងក្នុងពុទ្ធប្រវត្តិ ហើយមានចំណារឆ្នាំបញ្ជាក់ "ព.ស.២៥០២ ឆ្នាំ១៩៥៩" ក្បែរឈុតចុងបញ្ចប់នៃខ្សែរឿង។ ប៉ុន្តែគំនូរជួរខាងក្រោមដែលស្រង់យកពីរឿងជាតកស្ទើរតែទាំងអស់ បានគូរបន្ថែមឡើងវិញនៅរវាងឆ្នាំ២០០០ថ្ងាយ (រូបលេខ៧)។ ទន្ទឹមនឹងនេះនៅផ្ទៃជញ្ជាំងអមសងខាងទ្វារនីមួយៗ គេគូររូបយោធាសម័យសង្គមរាស្ត្រ រូបបុរសស្ត្រីស្លៀកពាក់បែបទំនើប និងរូបបុរសស្ត្រីស្លៀកពាក់របៀបពួកក្លឹងជាដើម។



រូបលេខ៧ គំនូររឿងជាតកគូរថ្មីតាមលំនាំគំនូរចាស់

ចំណែកឯគំនូរលើជញ្ជាំងដែលនិយាយអំពីរឿងពុទ្ធនៅក្នុងព្រះវិហារវត្តពុទ្ធា គឺចាប់ផ្តើមឡើងនៅលើជញ្ជាំងខាងត្បូងចុងខាងកើត សរុបមានចំនួន២៨ផ្ទាំង ពោលគឺផ្ទាំងទី១ "ទេវតាយាងសន្ទុសិតទេវបុត្រឱ្យចុតមកចាប់កំណើត" រហូតដល់ផ្ទាំងចុងក្រោយគឺ "ចែកព្រះសារីរិកធាតុ"។ ចាប់ផ្តើម និងបញ្ចប់រឿងបែបនេះ ហាក់ដូចពុំប្លែកពីការសង្កេតរបស់អ្នកស្រាវជ្រាវអំពីគំនូរនៅតាមវត្តឡើយ។[3] ប៉ុន្តែអ្វីដែលពិសេស និងគួរឱ្យកត់សម្គាល់ក្នុងគំនូរពុទ្ធប្រវត្តិនៃព្រះវិហារវត្តពុទ្ធា គឺការគូរបញ្ចូលព្រះឆាយាលក្ខណ៍អង្គព្រះមហាក្សត្រក្នុងឈុតសំខាន់យ៉ាងណាស់ពីរ "ព្រះអង្គយាងចូលបរិនិព្វានទៀបនគរកុសិនារា" និង "កាលថ្វាយព្រះភ្លើងដល់ព្រះសម្មាសម្ពុទ្ធ"។ ក្នុងឈុតដែលព្រះសម្មាសម្ពុទ្ធយាងចូលព្រះនិព្វាន វិចិត្រករគូរទិដ្ឋភាពទាំងមូលនៅមុខប្រាសាទអង្គរវត្ត ហើយគូរព្រះឆាយាលក្ខណ៍

[3] សូមអានបន្ថែម សាន ផល្លា ២០០៧: ១៨

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

***ព្រះបាទ នរោត្តម សុរាម្រឹត*** និង ***ព្រះមហាក្សត្រីយានី*** ព្រមទាំង ***ព្រះបាទ នរោត្តម សីហនុ*** គង់នៅក្រោយព្រះសពព្រះសម្មាសម្ពុទ្ធ។ ព្រះឆាយាលក្ខណ៍ ***ព្រះបាទ នរោត្តម សីហនុ*** គេគូរជាពីរអង្គ ពោលគឺមួយបែបទ្រង់អាវធំរបៀបផ្លូវការបែបអឺរ៉ុប និងមួយទៀតទ្រង់ព្រះភូសាកុតកពណ៌ស (រូបលេខ៨)។



*រូបលេខ៨ ព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រ និងព្រះមហាក្សត្រី ក្នុងគំនូរព្រះពុទ្ធចូលព្រះនិព្វាន*

រីឯនៅត្រង់ឈុតថ្វាយព្រះភ្លើងដល់ព្រះបរមសពព្រះសម្មាសម្ពុទ្ធ គេគូរព្រះឆាយាលក្ខណ៍ ***ព្រះបាទ នរោត្តម សីហនុ*** ទ្រង់ឈរ ព្រះពស្ត្រក្បិន និងព្រះភូសាផាយ (រូបលេខ៩)។ ព្រះឆាយាលក្ខណ៍បែបនេះ គេឃើញមានគូរច្រើនក្នុងព្រះវិហារកសាងឡើងក្នុងសម័យសង្គមរាស្ត្រនិយម។[4] ផ្សេងពីនេះ គេក៏សង្កេតឃើញផងដែរថា វិចិត្រករថែមទាំងមានគូររូបមហាត្ម:គន្ធី ដែលជាមេដឹកនាំដ៏ល្បីល្បាញរបស់ឥណ្ឌាកំពុងអង្គុយបញ្ឈរជង្គង់ លើកដៃប្រណម្យក្បែរថាសបាយ និង***ព្រះបាទ នរោត្តម សីហនុ*** ( ? ) ទ្រង់ព្រះពស្ត្រក្បិន ព្រះភូសាកុតក កាន់ភាជន៍បាយ រង់ចាំដាក់បាត្រព្រះសម្មាសម្ពុទ្ធនិមន្តមកក្រុងកបិលពស្តុ(រូបលេខ១០)។

---

[4] សូមអានបន្ថែម ព្រាប ចាន់ម៉ារ៉ា ២០២២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៩ ព្រះឆាយាលក្ខណ៍ ព្រះបាទនរោត្តម សីហនុ ក្នុងពិធីថ្វាយព្រះភ្លើងព្រះពុទ្ធ



រូបលេខ១០ រូបមហាគ្នះគន្ធីនិងព្រះឆាយាលក្ខណ៍ ព្រះបាទនរោត្តម សីហនុ រង់ចាំដាក់បាត្រព្រះពុទ្ធ

ក្រៅពីនេះ គេក៏សង្កេតឃើញវិចិត្រករគូរភ្ជាប់មន្ត្រីរាជការខ្មែរក្នុងសម្លៀកបំពាក់ផ្លូវការក្នុងឈុតផ្សេងៗទៀតនៃគំនូរដូចជា "ទ្រង់លើកផ្លូសម្ដែងឫទ្ធិ" ឬ "ពិធីអភិសេក" ជាដើម។ ផ្ទុយពីនេះចំពោះគំនូរនៅលើពិតានខាងលើ ដែលជាពិតានឈើ គេគូរតែព្រះអាទិត្យ ព្រះចន្ទ្រ និងទេវតាហោះហើយត្រដែតលើអាកាសប៉ុណ្ណោះ (រូបលេខ១១)។ ប៉ុន្តែបើគំនូរនៅលើបន្ទះក្ដារហប់ខ្យល់ជុំវិញ គេគូរទេសភាពនៃសង្គមមួយដែលមានរូបឡានម៉ូតូ ដើមត្នោត វាលស្រែ សត្វស្រុក និងសត្វព្រៃផ្សេងៗ ព្រមទាំងគំនូរពិសេសមួយបង្ហាញទិដ្ឋភាពមុខប្រាសាទអង្គរវត្ត (រូបលេខ១២)។ សូមបញ្ជាក់ថា ចំពោះព្រះវិហារបុរាណនៅទីនានា ត្រង់ហប់ខ្យល់នេះ គេច្រើនគូររឿងពុទ្ធប្រវត្តិ ឬរឿងជាតកត្រង់អន្ទើសំខាន់ណាមួយ ក្នុងទម្រង់ជាគំនូរបុរាណតូចៗយ៉ាងល្អវិចិត្រ។



រូបលេខ១១ គំនូរលើពិតានខាងក្នុងព្រះវិហារ



រូបលេខ១២ គំនូររូបអង្គរវត្តនៅលើហប់ខ្យល់

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សង្ខេបសេចក្តីមក ព្រះវិហារវត្តពុទ្ធា គឺជាសំណង់ឈើដ៏ល្អមួយនៅតាមវត្តអារាម ក្នុងសង្គមខ្មែរ ដែលត្រូវចាត់ទុកជាសំណង់បេតិកភណ្ឌ ប្រកបដោយតម្លៃនិងសិល្បៈដ៏សំខាន់របស់សហគមន៍។ ខ្លឹមសារគំនូរពាក់ព័ន្ធនឹងពុទ្ធប្រវត្តិ ឬរឿងជាតកនានាដែលលើកមកគូរបង្ហាញ ក៏មានរួមបញ្ចូលនូវទិដ្ឋភាពសង្គមខ្មែរមួយក្នុងអតីតកាល ជាពិសេស គឺព្រះរាជវត្តមានព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រ ព្រះមហាក្សត្រីខ្មែរ ព្រមទាំងបុគ្គលសំខាន់ដ៏ល្បីលើពិភពលោក ដែលគេអាចចាត់ទុកថាជាលក្ខណៈលេចធ្លោតែមួយគត់នៃព្រះវិហារវត្តពុទ្ធា។

## ឯកសារយោង


ព្រាប ចាន់ម៉ារ៉ា

២០១៥, "ផ្ទាំងមារ", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១០, ទំ. ២៤-៣០, យសោធរ, ភ្នំពេញ

២០២២, *ព្រះបរមរតនកោដ្ឋ ក្នុងគំនូរនៅតាមវត្ត*, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

សាន ផល្លា

២០០៧, *គំនូរនៅតាមវត្ត*, រៃយំ, ភ្នំពេញ

Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda*, Kam editions


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត